**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែធ្នូ ឆ្នាំ២០២០

នៅក្នុងខែធ្នូ ឆ្នាំ២០២០នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅៈ

### ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

**១.១** សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

ក-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន១លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៦ នីតិកាលទី៤ ចំនួន២លើក។

ខ-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ

-បានអនុញ្ញាតឱ្យឯកឧត្តម **Park Heung-Kyeong** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋកូរ៉េ ចូលជួបសម្តែងការគួរសម។

គ-សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខអាជ្ញាធរមូលដ្ឋាន កងកម្លាំង និងប្រជាពលរដ្ឋ នៅសង្កាត់ស្នោរ ខណ្ឌកំបូល រាជធានីភ្នំពេញ

-បានអញ្ជើញចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខអាជ្ញាធរមូលដ្ឋាន កងកម្លាំង និងប្រជាពលរដ្ឋ នៅសង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

ឃ-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញចូលរួមពិធីដង្ហែព្រះរាជដំណើរ**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជពិធីសម្ពោធអគារពុទ្ធិកវិទ្យាល័យជម្ពូវ័ន្តសែនជ័យ និងសមិទ្ធផលនានា នៅវត្តជម្ពូវ័ន្ត សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ង-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៥១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៥ច្បាប់។

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា អនុប្រធានទី១ព្រឹទ្ធសភា**

ក-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៦ នីតិកាលទី៤ ចំនួន២លើក ក្រោមអធិបតីភាពសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា។

ខ-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញចុះពិនិត្យការសាងសង់សមិទ្ធផលនានា ព្រមទាំងនាំយកសម្ភារ បរិក្ខារ និងបច្ច័យទៅប្រគេនព្រះសង្ឃ នៅវត្តទេពនិម្មិត ឃុំក្របៅ ស្រុកកំចាយមារ និងវត្តពង្ររង្សី ឃុំគោកគង់កើត ស្រុកកញ្ជៀច ខេត្តព្រៃវែង។

គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៧ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៣៥ច្បាប់។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ខេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

ក-សកម្មភាពចូលរួមប្រជុំ

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៦ នីតិកាលទី៤ ចំនួន២លើក ក្រោមអធិបតីភាពសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា។

ខ-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញចូលរួមពិធីបុណ្យសពឧបាសក **លាវ ហ៊ាន** នៅវត្តនាគវ័ន រាជធានីភ្នំពេញ។

គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១០ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១០ច្បាប់។

## ២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន២លើក

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានបើកកិច្ចប្រជុំចំនួន២លើក ដើម្បីពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៧ច្បាប់ ដូចខាងក្រោមៈ

១-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

២-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩

៣-សេចក្តីព្រាងច្បាប់ស្តីពី មូលបត្ររដ្ឋ

៤-សេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីការទទួលស្គាល់ទៅវិញទៅមកលើការផ្តល់អាជ្ញាបណ្ណក្រុមអាកាសយានិក

៦-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើៈ

១-ពិធីសារទី៣ស្តីពី សិទ្ធិសហការលើជើងហោះហើរក្នុងស្រុកក្នុងរង្វង់ទឹកដីនៃប្រទេសជាសមាជិកអាស៊ានណាមួយ

២-ពិធីសារទី៤ស្តីពី សិទ្ធិហោះហើរកូធ័រមីណាល រវាងអាកាសយានដ្ឋាននៅក្នុងទឹកដីនៃប្រទេសជាសមាជិកអាស៊ាន

៧-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៩ និងទី១០ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម។

## ៣.សម័យប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន២លើក

ព្រឹទ្ធសភាបានបើកសម័យប្រជុំលើកទី៦ នីតិកាលទី៤ ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ចំនួន៧ច្បាប់ដូចខាងក្រោមៈ

១-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

២-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩

៣-សេចក្តីព្រាងច្បាប់ស្តីពី មូលបត្ររដ្ឋ

៤-សេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពី

ការទទួលស្គាល់ទៅវិញទៅមកលើការផ្តល់អាជ្ញាបណ្ណក្រុមអាកាសយានិក

៦-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ៖

១-ពិធីសារទី៣ស្តីពី សិទ្ធិសហាការលើជើងហោះហើរក្នុងស្រុកក្នុងរង្វង់ទឹកដីនៃប្រទេសជាសមាជិកអាស៊ានណាមួយ

២-ពិធីសារទី៤ស្តីពី សិទ្ធិហោះហើរកូផ៌រមីណល រវាងអាកាសយានដ្ឋាននៅក្នុងទឹកដីនៃប្រទេសជាសមាជិកអាស៊ាន

៧-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៩ និងទី១០ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពី សេវាកម្ម។

## ៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ចនិងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៤.១ មុខងារនីតិកម្ម

គណៈកម្មការជំនាញព្រឹទ្ធសភា បានប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ចំនួន៧ច្បាប់។

### ៤.២ មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន១ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយចំនួន១ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន១ករណី និងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន១ករណី ព្រមទាំងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការដើម្បីជូនជ្រាបចំនួន២ករណី។

-បានប្រជុំពិភាក្សាការងាររៀបចំគ្រឿងឥស្សរិយយសសម្រាប់បំពាក់ជូនសមាជិកព្រឹទ្ធសភានៅពាក់កណ្តាលនីតិកាលទី៤ ក្រោមអធិបតីភាពឯកឧត្តម **ជា ជេដ្ឋ** ប្រធានគណៈកម្មការរៀបចំគ្រឿងឥស្សរិយយស និងជាប្រធានគណៈកម្មការទី២ ព្រឹទ្ធសភា

-បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំត្រៀមចុះជួបពិភាក្សាការងារជាមួយការិយាល័យជំនាញចំណុះរដ្ឋបាលខណ្ឌសែនសុខ និងត្រៀមរៀបចំវេទិការបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ នាពេលខាងមុខ

-បានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយលោកមេឃុំ ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ និងប្រធានប៉ុស្តិ៍នគរបាលឃុំ ដើម្បីឈ្វេងយល់អំពីការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព វិធានការបង្ការទប់ស្កាត់

ការរីករាលដាលជំងឺកូវីដ-១៩ និងការអភិវឌ្ឍមូលដ្ឋាន នៅឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប

-បានអញ្ជើញចូលរួមជាវាគ្មិនក្នុងវេទិកាស្តីពី យុទ្ធនាការនារីវ័យក្មេងឆ្ពោះទៅភាពជាអ្នកដឹកនាំ ក្រោមអធិបតីភាពលោកជំទាវ **ឡោក ខេង** ប្រធានគណៈកម្មការទី៨ រដ្ឋសភា នៅសាលមហោស្រព ខេត្តក្រចេះ

-បានអញ្ជើញចូលរួមជាវាគ្មិនក្នុងអង្គសិក្ខាសាលាផ្សព្វផ្សាយអំពីលទ្ធផលនៃរបាយ-ការណ៍សិក្សាវាយតម្លៃតម្រូវការរបស់សភាកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា តាមប្រព័ន្ធវីដេអូ នៅសាលសិក្ខាសាលាខាងជើងព្រឹទ្ធសភា

-បានអញ្ជើញចូលរួមជាអធិបតី និងផ្តល់មតិណែនាំ ក្នុងសិក្ខាសាលាផ្សព្វផ្សាយស្តីពីលទ្ធផលអនុវត្តសាកល្បងលើសៀវភៅណែនាំការអភិវឌ្ឍសហគមន៍លំនៅដ្ឋានបណ្តោះអាសន្ន និងការចែករំលែកបទពិសោធន៍ការអភិវឌ្ឍសហគមន៍លំនៅដ្ឋានបណ្តោះអាសន្ន

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ចែកអំណោយ និងអប់រំផ្សព្វផ្សាយវិធីបង្ការនិងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ដល់ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងចូលរួមពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន៧៤លើក។

## ៤.៣ កិច្ចសហប្រតិបត្តិការអន្តរជាតិ

-លោកជំទាវ **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូសភាជាតិកម្ពុជា(APF) ចូលរួមកិច្ចប្រជុំក្រុមការងាររៀបចំគោលនយោបាយប្រយុទ្ធប្រឆាំងការបៀតបៀនផ្លូវចិត្ត និងផ្លូវកាយចំពោះស្ត្រី នៃបណ្តាញស្ត្រីសភាប្រើភាសាបារាំង ក្រោមអធិបតីភាពលោកជំទាវ **Maryse Gaudreaut** ប្រធានបណ្តាញស្ត្រីនៃសភាប្រើភាសាបារាំង (APF) តាមប្រព័ន្ធវិដេអូ ដែលផ្សាយចេញពីទីក្រុងប៉ារីស ប្រទេសបារាំង នៅសាលប្រជុំពិសេសព្រឹទ្ធសភា

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ បានទទួលជួបក្រុមអ្នកវិនិយោគចិន និងកូរ៉េខាងត្បូង ពិភាក្សាការងារ ដើម្បីរកឱកាសបណ្ដាក់ទុនវិនិយោគនៅកម្ពុជាលើវិស័យកសិកម្ម កសិឧស្សាហកម្ម និងកែច្នៃ និងបានជួបពិភាក្សាការងារជាមួយក្រុមនិស្សិតអំពីគោលបំណងនៃការបង្កើតបណ្ណាល័យអេឡិចត្រូនិច។

ថ្ងៃអង្គារ ៧រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែមករា ឆ្នាំ២០២១

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

*កិត្តិសង្គហបណ្ឌិត* **តេព ខុន**

*ចម្លងជូន*

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ខ្ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*